**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣១...សសរ.......

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តមណ្ឌលគិរី** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. **ឯកឧត្តម ងី ច័ន្ទ្រផល** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ប្រធាន |
| ២. **ឯកឧត្តម ថោ ជេដ្ឋា** | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣. **ឯកឧត្តម សេន សុវណ្ណ** | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤. **ឯកឧត្តម អេង កុកថាយ** | រដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. **ឯកឧត្តម ថៅ សុខមុនី** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦. **ឯកឧត្តម សួន សុខឃីម** | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ៧. **ឯកឧត្តម ជា ជុន** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨. **ឯកឧត្តម សេង សុវណ្ណារ៉ា** | អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិក |
| ៩. **ឯកឧត្តម ជា ណារ៉េត** | អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | សមាជិក |
| ១០. **ឯកឧត្តម ថុក សុខុម** | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ១១. **ឯកឧត្តម វ័ន្ន វិរៈ** | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១២. **ឯកឧត្តម ឡុង សេង** | អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ១៣. **ឯកឧត្តម លឹម គង់** | អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១៤. **ឯកឧត្តម ចាប ឫទ្ធី** | អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៥. **ឯកឧត្តម ភឿង សុភ័ណ្ឌ** | ទីប្រឹក្សា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៦. **ឯកឧត្តម យក់ ប៊ុនស៊ិន** | ទីប្រឹក្សា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១៧. **ឯកឧត្តម អ៊ុន ពៅ** | ទីប្រឹក្សា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១៨. **ឯកឧត្តម ផាន់ សុធា** | ទីប្រឹក្សា ក្រសួងមហាផ្ទៃ | សមាជិក |
| ១៩. **ឯកឧត្តម ប៉ុល សុផា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុក ជាអគ្គនាយក នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២០. **ឯកឧត្តម ឈឹម សារ៉េត** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២១. **ឯកឧត្តម កែវ គង់** | អគ្គនាយក នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ២២. **ឯកឧត្តម ហាប់ ទូច** | អគ្គនាយក នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២៣. **ឯកឧត្តម ជិត គន្ធុល** | អគ្គាធិការ នៃក្រសួងការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈ | សមាជិក |
| ២៤.**ឯកឧត្តម ទិន ពន្លក** | អគ្គលេខាធិការ នៃក្រសួងបរិស្ថាន | សមាជិក |
| ២៥. **ឯកឧត្តម ចឹក លីម** | អគ្គនាយករង នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២៦. **ឯកឧត្តម ទេព ពុទ្ធា** | អគ្គនាយករង នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២៧. **ឯកឧត្តម ហ៊ិន យុវនា** | អនុប្រធានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ | សមាជិក |
| ២៨. **ឯកឧត្តម ឧត្តមសេនីយ៍ឯក មិន នឹម** | មេបញ្ជាការរងកងទ័ពជើងគោក នៃក្រសួងការពារជាតិ | សមាជិក |
| ២៩. **ឯកឧត្តម ឧត្តមសេនីយ៍ទោ ឡាយ ប៊ុណ្ណារិទ្ធ** | អគ្គាធិការរង នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៣០. **លោក ទូន ភិរម្យ** | អគ្គនាយករង នៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៣១. **លោក គីម ទីផល្លី** | អគ្គនាយករង នៃ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៣២. **លោក ឡុង សារ៉ែន** | អគ្គនាយករង នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

| | | |
|---|---|---|
| ៣៣. **លោក ខឹម បូរ៉ាណា** | អគ្គនាយករង នៃក្រសួងព័ត៌មាន | សមាជិក |
| ៣៤. **លោក គង់ បូលីន** | អគ្គនាយករង នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៣៥. **លោក លឿង រដ្ឋា** | អគ្គនាយករង នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៣៦. **លោក សន សំអឿន** | អគ្គាធិការរង នៃក្រសួងសុខាភិបាល | សមាជិក |
| ៣៧. **លោក ភី សុគន្ធ** | អគ្គលេខាធិការរង នៃក្រសួងកិច្ចការនារី | សមាជិក |
| ៣៨. **លោក ង៉ិយ ធឿន** | នាយករងសាលាភូមិន្ទរដ្ឋបាល នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៣៩. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |
| ៤០. តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | | សមាជិក |

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រី ឲ្យចូលរួមក្នុងក្រុមការងារ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន រដ្ឋបាលខេត្តមណ្ឌលគិរី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*